UNITED NATIONS CAMBODIA

**សុន្ទរកថា**

**របស់**

**លោកស្រី** Pauline Tamesis

**អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា**

# កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុក ក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ ១០ (COVID 19)

*ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៩ ព្រឹក*

*អាគារ ទ ទីស្តីការក្រសួងមហាផ្ទៃ*

(សូមផ្ទៀងផ្ទាត់ជាមួយខ្លឹមសារនៃការថ្លែងជាក់ស្តែង)

-------------

*សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមេត្រី!*

តាងនាមឱ្យអង្គការសហប្រជាតិប្រចាំកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណចំពោះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាមន្ត្រីក្រសួងមហាផ្ទៃ ដែលបានដឹកនាំរៀបចំកិច្ចប្រជុំដ៏មានសារៈសំខាន់នាថ្ងៃនេះ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មរបស់ក្រុមប្រឹក្សាជាតិ បណ្តាក្រសួង និងអាជ្ញាធរជាតិពាក់ព័ន្ធ និងទន្ទឹងរងចាំកិច្ចពិភាក្សាប្រកបដោយផ្លែផ្កាព្រមទាំងភាពជាដៃគូដែលនៅតែបន្ត។

មុនពេលចាប់ផ្តើម ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងដ៏អស្ចារ្យរបស់ លោកជំទាវ ជូ ប៊ុន អេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងក្រុមការងាររបស់លោកជំទាវ ក្នុងការឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ពលករទេសន្តប្រវេសន៍កម្ពុជា ដែលបានវិលត្រលប់មកកម្ពុជា និងសហគមន៍របស់ពួកគេ ក្នុងបរិបទនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ។ យើងក៏សូមសម្តែងនូវការដឹងគុណដល់ លោកជំទាវ និងក្រុមការងារក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដ៏មានសារសំខាន់មួយនេះជាមួយនឹងសហការីរបស់អង្គការសហប្រជាជាតិ។ សូមអរគុណ លោកជំទាវ!

*សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី !*

*ឯកឧត្តម លោក លោកស្រី !*

ពិភពលោកកំពុងប្រឈមនឹងការគំរាមកំហែងពីជំងឺកូវីដ១៩ ដែលពុំធ្លាប់មានពីមុនមក។ ការគំរាមកំហែងនេះជាវិបត្តដែលខ្លាំងជាងគេបំផុត ដែលពិភពលោកពុំធ្លាប់បានជួបប្រទះចាប់តាំងពីសង្គ្រាមលោកលើកទី២។ វាជាវិបត្តិសុខភាពជាសកល ដែលមិនដូចគ្នាទៅនឹងវិបត្តផ្សេងៗទៀតទេ។ វិបត្តិមួយនេះរាតត្បាតលើមនុស្ស បង្កឱ្យមានអស្ថេរភាពសេដ្ឋកិច្ចសកល ធ្វើឱ្យក្រឡាប់ចាក់ដល់ជីវិតមនុស្សរាប់ពាន់លាននាក់ជុំវិញពិភពលោក។

ប្រទេសនីមួយៗកំពុងរិះរកមធ្យោបាយដោះស្រាយ ឬត្រៀមរៀបចំខ្លួនទទួលផលវិបាកដ៏ធ្ងន់ធ្ងរនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ នេះ ៖ ការបាត់បង់ជីវិតមនុស្សរាប់សែននាក់ ការបែកបាក់គ្រួសារ មន្ទីរពេទ្យមានអ្នកជំងឺច្រើនលើសលប់ ការងារច្រើនលើសលប់សម្រាប់បុគ្គលិកសុខាភិបាល។

ខណៈដែលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ជាវិបត្តដំបូងបំផុត និងអាក្រក់បំផុត ហើយផលវិបាករបស់វាកាន់តែធំធេង។ យើងមើលឃើញរួចហើយនូវផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមដ៏ធំធេងដែលរដ្ឋាភិបាលជុំវិញពិភពលោកប្រឹងប្រែងស្វែងរកការឆ្លើយតបដែលមានប្រសិទ្ធភាពបំផុតចំពោះការកើនឡើងនៃភាពអត់ការងារធ្វើ និងការធ្លាក់ចុះនៃសេដ្ឋកិច្ច។ អង្គការពលកម្មអន្តរជាតិ រំពឹងថា ក្នុងសកលលោកទាំងមូល ម៉ោងធ្វើការស្មើនឹង ១៩៥លាន សម្រាប់បុគ្គលិកពេញម៉ោង នឹងត្រូវបាត់បង់ក្នុងត្រីមាសទី២ និងខាតបង់ប្រាក់ចំណូលប្រមាណជា ៣.៤ ទ្រីលានដុល្លាអាមេរិច ត្រឹមដំណាច់ឆ្នាំនេះ។

ស្ត្រីនឹងទទួលរងប៉ះពាល់យ៉ាងខ្លាំងដោយសារវិបត្តនេះ។ ស្ត្រីមានតួនាទីមិនស្មើភាពគ្នាក្នុងការឆ្លើយតបចំពោះជំងឺនេះ ដោយរួមបញ្ចូលទាំងបុគ្គលិកសុខាភិបាលជួរមុខ និងអ្នកថែទាំនៅតាមផ្ទះ។ ស្ត្រីធ្វើការងារមិនស្មើភាពគ្នាក្នុងទីផ្សារការងារដែលមិនមានសុវត្ថិភាព និងទទួលរងប៉ះពាល់សេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺកូវីដ-១៩ កាន់តែខ្លាំង។ យើងក៏មើលឃើញផងដែរថា ស្ត្រីកំពុងប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារដោយសារតែពួកគេស្ថិតនៅក្នុងផ្ទះជានិច្ច។

ហានិភ័យដែលបង្ករឡើងដោយជំងឺកូវីដ-១៩ ចំពោះកុមារក៏មានទ្រង់ទ្រាយធំផងដែរ។ ក្នុងវិបត្តិមួយនេះនឹងធ្វើអោយកុមារជាច្រើន ទទួលបានការអប់រំមានកម្រិត ឬមិនទទួលបានការអប់រំ ឬធ្លាក់ចុះការសិក្សាកាន់តែខ្លាំងជាងមិត្តភ័ក្ត្ររបស់ពួកគេ។ បច្ចុប្បន្ន កុមារជាង ៨០០ លាននាក់ កំពុងនៅក្រៅសាលា ហើយពួកគេភាគច្រើនពឹងផ្អែកលើការទទួលបានអាហារពីសាលា។ កុមារត្រូវទទួលបានអាហារ និងការសិក្សាស្មើៗគ្នា តាមរយៈការកាត់បន្ថយគំលាតឌីជីថល និងការកាត់បន្ថយតម្លៃនៃការតភ្ជាប់។

*សម្តេច!*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ដូចនឹងបណ្តាប្រទេសជុំវិញពិភពលោក រាជរដ្ឋាភិបាលកម្ពុជាប្រឈមនឹងបញ្ហាដ៏ស្មុគស្មាញក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ មិនត្រឹមតែក្នុងវិស័យសុខាភិបាលប៉ុណ្ណោះទេ ថែមទាំងក្នុងវិស័យដទៃទៀត ដូចជា វិស័យអប់រំ ទេសចរណ៍ ពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងឧស្សាហកម្មផងដែរ។

ទោះបីជាមានករណីនៃជំងឺកូវីដ-១៩ ចំនួនត្រឹមតែ ១២២ គិតត្រឹមថ្ងៃទី ២០ ខែមេសា ក៏វិបត្តិដ៏ធំនៃជំងឺកូវីដ-១៩ នេះ នឹងប៉ះពាល់ដល់ប្រជាពលរដ្ឋទាំងអស់ក្នុងប្រទេសកម្ពុជា។ ពិតណាស់ ក្រុមប្រជាពលរដ្ឋជាក់លាក់មួយចំនួននឹងទទួលរងផលប៉ះពាល់ជាងក្រុមដទៃទៀត។

ផលប៉ះពាល់ដែលមានលក្ខណៈមិនស្មើភាពគ្នានេះកើតមានដោយសារកត្តាជាច្រើន។ ប្រជាពលរដ្ឋជាច្រើន ងាយរងគ្រោះដោយសារពួកគេមិនមានស្ថេរភាពប្រាក់ចំណូល និងការការពារផ្នែកសុខភាព។ ប្រជាពលរដ្ឋជាង៦០% ឬ យ៉ាងហោចណាស់ប្រជាពលរដ្ឋកម្ពុជាប្រមាណ ១០លាននាក់ មិនមាន

ការការពារផ្នែកហិរញ្ញវត្ថុនៅពេលដែលពួកគេធ្លាក់ខ្លួនឈឺ។ មានន័យថា អ្នកដែលរងផលប៉ះពាល់ខ្លាំងជាងគេ គឺនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាកម្មករទេសន្តប្រវេសន៍ ស្ត្រី កុមារ ជនមានពិការភាព ចាស់ជរា និងអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងក្រុមគ្រួសាររបស់ពួកគេ។ ប្រសិនបើពួកគេមិនមានលទ្ធភាពរកប្រាក់ចំណូលប្រចាំថ្ងៃ ឬស្វែងរកការថែទាំនៅពេលពួកគេឈឺនោះទេ វិធានការសុខភាពសាធារណៈដើម្បីបញ្ឈប់ការចម្លងជំងឺកូវីដ១៩ នឹងមិនទទួលបានជោគជ័យឡើយ។

ដោយសារបញ្ហានេះ កិច្ចពិគ្រោះយោបល់ថ្ងៃនេះ ដោយផ្តោតលើបញ្ហាប្រឈមជាក់លាក់ក្នុងការគ្រប់គ្រងហានិភ័យចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះទាំង ជាពិសេសពលកចំណាកស្រុកដែលទើបវិលត្រលប់មកវិញ គ្រួសារ និងសហគមន៍របស់ពួកគេ គឺជាឱកាសដ៏សំខាន់ដើម្បីជួយឱ្យយើងរៀបចំវិធានការក្នុងការបង្ការ ទប់ស្កាត់ ការផ្ទុះរាតត្បាតទ្រង់ទ្រាយធំក្នុងសហគមន៍ ជាពិសេសផ្តោតលើប្រជាពលរដ្ឋងាយរងគ្រោះ។

ចំពោះបញ្ហានេះ យើងត្រូវបានលើកទឹកចិត្តតាមរយៈការប្តេជ្ញាចិត្តផ្នែកនយោបាយកម្រិតខ្ពស់ តាមរយៈ ការបង្កើតគណៈកម្មាធិការជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ គណៈកម្មាធិការអន្តរក្រសួង ទទួលបន្ទុកជងឺកូវីដ-១៩ និងគណៈកម្មាធិការរាជធានី ខេត្ត សម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ។

វិធានការជាច្រើនត្រូវដាក់ចេញ មិនត្រឹមតែដើម្បីទប់ស្កាត់ការចម្លងនៃជំងឺកូវីដ-១៩ ប៉ុណ្ណោះទេ ថែមទាំងដើម្បីដោះស្រាយផលវិបាកផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើនផងដែរ។

យើងសូមសំដែងនូវការពេញចិត្តទៅលើការដឹកនាំរបស់ក្រសួងមហាផ្ទៃ និងអាជ្ញាធរថ្នាក់ក្រោមជាតិសម្រាប់កិច្ចខិតខំប្រឹងប្រែងពង្រឹងការគ្រប់គ្រង ការសម្របសម្រួល និងការតាមដានសុខភាពរបស់ពលករដែលទើបតែត្រលប់ពីប្រទេសថៃវិញ។

ការវិលត្រលប់របស់ពលករកម្ពុជារាប់សែននាក់ពីប្រទេសថៃថ្មីៗ បានបង្កើននូវក្តីកង្វល់អំពីលទ្ធភាពនៃការចម្លងជំងឺជាចង្កោមក្នុងសហគមន៍របស់ពួកគេ ក៏ដូចជាការចម្លងក្នុងចំណោមអ្នកវិលត្រលប់មកវិញក្នុងពេលធ្វើដំណើរទៅកាន់ផ្ទះរបស់ពួកគេ។ ពលករភាគច្រើនបានវិលត្រលប់ទៅកាន់តំបន់ជនបទ

ក្នុងប្រទេសកម្ពុជា ដែលធ្វើឱ្យមានការលំបាកក្នុងការតាមដាន ការធ្វើតេស្ត ឬការព្យាបាលជំងឺកូវីដ-១៩ ក្នុងករណីកើតមានឡើង។

យើងក៏ដឹងផងដែរថា មិនត្រឹមតែពលករចំណាកស្រុកក្រៅប្រទេសដែលវិលត្រលប់មកវិញទេដែលអាចនឹងបាត់បង់ជីវភាព និងប្រាក់ចំណូល។ ពលករចំណាកស្រុកក្នុងប្រទេសជាច្រើន នៅក្នុងវិស័យសេវាកម្មទេសចរណ៍ កាត់ដេរ និងសំណង់ ក៏ត្រូវបានទទួលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ផងដែរ។ ការកាត់បន្ថយការផ្ញើរប្រាក់ទៅក្រុមគ្រួសាររបស់ពួកគេនៅតំបន់ជនបទ បង្កើតបានជាផលប៉ះពាល់ជាល្បាក់។

ខណៈដែលការសិក្សា វាយតម្លៃ ទៅលើផលប៉ះពាល់ និងតម្រូវការរបស់ពលករដែលបានវិលត្រឡប់កំពុងត្រូវបានធ្វើឡើង យើងបានឃើញរួចជាស្រេចនូវបញ្ហាប្រឈមជាច្រើន រួមជាមួយនឹងការបាត់បង់ជីវភាព។

*សម្តេច!*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

អង្គការសហប្រជាជាតិប្រចាំកម្ពុជាក្រោមការដឹកនាំបច្ចេកទេសរបស់អង្គការសុខភាពពិភពលោក និងអង្គការ IOM បាន និងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ជាពិសេសជាមួយលោកជំទាវ ជូ ប៊ុន អេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីកៀងគរការគាំទ្រដល់ពលករទេសន្តប្រវេសន៍ដែលវិលត្រឡប់ និងស្នាក់នៅក្នុងសហគមន៍របស់ពួកគេ។

ក្នុងន័យនេះ ក្រុមបច្ចេកទេសចំនួនពីរត្រូវបានបង្កើតឡើងនៅក្នុងអង្គការសហប្រជាជាតិដើម្បីផ្តោតលើ៖ (១) សុខភាព និងការការពារ និង (២) សន្តិសុខស្បៀង និងជីវភាព។ ក្រុមការងារទាំងពីរត្រូវបានធ្វើការដោយមានទំនាក់ទំនងនឹងគ្នា។

*ក្រុមការងារទទួលបន្ទុកសុខភាព និងការការពារ* ៖ សហដឹកនាំដោយអង្គការសុខភាពពិភពលោក និងអង្គការ IOM ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការឆ្លើយតបជាសកលដើម្បីស្វែងរក បញ្ឈប់ បង្ការការរាតត្បាតនៃជំងឺកូវីដ-១៩ និងត្រៀមបម្រុងសម្រាប់ការចម្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ។

*ក្រុមការងារទទួលបន្ទុកសន្តិសុខស្បៀង និងជីវភាព* ៖ សហដឹកនាំដោយកម្មវិធីស្បៀងអាហារពិភពលោក (WFP) និង អង្គការ FAO ដោយគាំទ្រធ្វើការវិភាគភាពងាយរងគ្រោះ តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការថ្នាក់ក្រោមជាតិទៅលើការធ្វើបំលាស់ទីរបស់ប្រជាជន និងព័ត៌មានលំអិតនៃពលករ និងសហគមន៍។ ក្រុមការងារនេះក៏គាំទ្រទៅលើការរៀបចំម៉ាក្រូសេដ្ឋកិច្ច ប្រព័ន្ធស្បៀង និងការវិភាគការគាំពារសង្គម និងការអន្តរាគមន៍។

ទន្ទឹមគ្នានេះ អង្គការសហប្រជាជាតិក្រោមការដឹកនាំបច្ចេកទេសរបស់ អង្គការ UNICEF និងអង្គការសុខភាពពិភពលោក បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅលើការផ្សព្វផ្សាយពីហានិភ័យ ការចូលរួមរបស់សហគមន៍ និងការកៀងគរដើម្បីឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ។

នៅពេលដែលស្ថានការវិវឌ្ឍន៍ វាចាំបាច់ក្នុងការប្រាស្រ័យទាក់ទងជាមួយសាធារណៈ នូវអ្វីដែលដឹង អ្វីដែលមិនដឹង និងអ្វីដែលកំពុងធ្វើ។ រួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា យើងនឹងខិតខំប្រឹងប្រែងដើម្បីធានាបាននូវការជឿទុកចិត្ត តម្លាភាព សមធម៌ បរិយាប័ន្ន និងការការពារជុំវិញការត្រៀមបម្រុង ការឆ្លើយតប និងការស្តារឡើងវិញ។ ការទទួលបានព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា មិនទុកឱ្យនរណាម្នាក់នៅឯកាក្នុងការធ្វើផែនការត្រៀមបម្រុង និងការឆ្លើយតប រួមទាំងការសម្របសម្រួលព័ត៌មានសម្រាប់មនុស្សដែលមានតំរូវការ និងពិការភាពជាក់លាក់ ដូចជាមនុស្សពិការភ្នែក និងត្រចៀក ជាដើម។

សហការីរបស់ខ្ញុំនឹងផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតនៅក្នុងបទអន្តរាគមន៍របស់ពួកគេ។

ការគាំទ្ររបស់អង្គការសហប្រជាជាតិ ក្នុងការគ្រប់គ្រងហានិភ័យចំពោះការវិលត្រឡប់របស់ពលករ និងសហគមន៍របស់ពួកគេ ក៏មានទំនាក់ទំនងគ្នាជាមួយនឹងការខិតខំប្រឹងប្រែងរបស់ពួកយើង ក្នុងការគាំទ្រជាបន្ទាន់ទ្រង់ទ្រាយធំ និងការឆ្លើយតបការការពារផ្នែកសង្គម ដែលមានលក្ខណៈសម្របសម្រួល។

យើងកំពុងធ្វើការសម្របសម្រួលការងារនេះយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ វិធានការណ៍ការពារសុខភាព និងសង្គម នៅក្នុងប្រទេសដទៃទៀត បានបង្ហាញពីភាពចាំបាច់ក្នុងការទប់ស្កាត់នឹងវីរុស តាមរយៈការផ្តល់នូវសុវត្ថិភាពប្រាក់ចំណូលដល់អ្នកដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុត និងដើម្បីធានាថា សេដ្ឋកិច្ចអាចទ្រទ្រង់មិនត្រឹមតែក្នុងពេលបច្ចុប្បន្ន ប៉ុន្តែថែមទាំងអាចជួយពេលមានវិបត្តិពេលអនាគតទៀតផង។

*សម្តេច!*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ជំងឺកូវីដ -១៩ គឺជាវិបត្តិពិភពលោកដ៏សាហាវមួយ ប៉ុន្តែ វាអាចបង្ហាញនូវឱកាសមួយប្រសិនបើយើងចាប់យក ដើម្បីសិក្សារៀនសូត្រពីវិបត្តិនេះ និងធ្វើការកែលម្អ។

កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីត្រៀមបម្រុង និងឆ្លើយតប ទៅនឹងជំងឺកូវីដ-១៩ អាចត្រូវបានពង្រីកបន្ថែមទៀត ដើម្បីកសាងប្រព័ន្ធការពារសុខភាព និងសង្គម ឱ្យកាន់តែរឹងមាំសម្រាប់ប្រទេស និងសង្គមដែលមានភាពធន់ជាងមុន។

កិច្ចខិតខំប្រឹងប្រែង និងការវិនិយោគ ដ៏ធំធេងបែបនេះ អាចជាមធ្យោបាយ ដែលប្រទេសកម្ពុជានឹងមានលទ្ធភាពប្រសើរជាងមុនក្នុងការប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានាពេលអនាគត។

ប្រទេសកម្ពុជា អាចប្រែក្លាយបញ្ហាប្រឈមទាំងនេះទៅជាឱកាស សម្រាប់ពង្រឹង និងផ្លាស់ប្តូរប្រព័ន្ធសុខាភិបាលរបស់ប្រទេស។ ដូច្នេះការវិនិយោគក្នុងការត្រៀមបម្រុង គឺពិតជាមានសារៈសំខាន់ណាស់។ វាមិនសំដៅតែទៅលើសាច់ប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពេលវេលា ការខិតខំប្រឹងប្រែង និងប្រព័ន្ធដែលយើងត្រូវដាក់ឱ្យដំណើរការ ដើម្បីអាចឆ្លើយតបបានកាន់តែប្រសើរឡើងនាពេលបច្ចុប្បន្ន និងទៅអនាគត។ ការផ្តល់ថវិកាសម្រាប់ការឆ្លើយតបបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ពិតជាសំខាន់ ប៉ុន្តែ និរន្តរភាព យុទ្ធសាស្ត្រ និងការវិនិយោគរយៈពេលវែងនៅក្នុងប្រព័ន្ធសុខាភិបាលកម្ពុជាក៏មានសារៈសំខាន់ផងដែរ។ ការវិនិយោគនេះនឹងធានាបាននូវប្រព័ន្ធសុខាភិបាលដែលមានស្ថេរភាព និងរឹងមាំ។ ការវិនិយោគនេះនឹងធានាថា អាចគាំទ្រដល់ការថែទាំសុខភាពបន្ត មិនត្រឹមតែសុខភាព

បន្តពូជ មាតា ទារក សុខភាពកុមារ និងមនុស្សវ័យជំទង់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្លាស់ប្តូរដើម្បីបំពេញតំរូវការនាពេលអនាគតសម្រាប់ចាស់ជរា និងជំងឺឆ្លងមិនឆ្លង។

ដើម្បីសម្រេចបានគោលដៅនេះ វាជាការចាំបាច់ណាស់ក្នុងការអនុវត្តវិធីសាស្ត្រ«ផ្តោតលើពហុវិស័យ» ប្រសិនបើ យើងចង់យកជ័យជំនះលើរោគរាតត្បាតជាសកលប្រកបដោយប្រសិទ្ធភាព។

យើងត្រូវតែធ្វើការរួមគ្នា រួបរួមគ្នា ដោយប្រើប្រាស់ធនធាន និងសមត្ថភាពទាំងអស់របស់យើង ដើម្បីការពារប្រជាជនកម្ពុជា។

យើងមិនអាចទទួលបានជោគជ័យដោយធ្វើការតែម្នាក់ឯងបានឡើយ ប៉ុន្តែរួមគ្នា យើងនឹងអាចទទួលបានជោគជ័យ។

*សម្តេច!*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ប្រសិនបើ សម្តេច អនុញ្ញាត ខ្ញុំសូមអញ្ជើញសហការីរបស់ខ្ញុំធ្វើបទបង្ហាញខ្លីៗអំពីការងារដែលពួកគេកំពុងដឹកនាំ៖

ទី១. លោកស្រី វេជ្ជបណ្ឌិត Ailan Li ប្រធានអង្គការសុខភាពពិភពលោក នឹងធ្វើបច្ចុប្បន្នភាពស្ថានភាពនៅថ្នាក់ជាតិ និងសកល និងយុទ្ធសាស្រ្តជាតិក្នុងការឆ្លើយតប និងការត្រៀមបម្រុង។

ទី២. លោកស្រី Kristin PARCO ប្រធានបេសកកម្មអង្គការ IOM នឹងបង្ហាញអំពីភាពងាយរងគ្រោះក៏ដូចជាការឆ្លើយតប និងការការពារសុខភាព ចំពោះពលករទេសន្តប្រវេសន៍ដែលទើបវិលត្រលប់មកវិញ។

ទី៣. លោកស្រី Francesca ERDELMANN នាយិកាប្រចាំប្រទេសកម្ពុជា របស់ WFP នឹងបង្ហាញអំពីការឆ្លើយតបទៅលើសន្តិសុខស្បៀង និងជីវភាពរស់នៅ។

សូមអរគុណច្រើន!